**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**

**អំពើជួញដូរមនុស្ស**

លេខ......៧៨១/២២......រ.ប.ក

# របាយការណ៍ខែតុលា

# ស្តីពី

# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែវិច្ឆិកា ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេស រុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឲ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច នឹងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ

ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** ៖ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

### ខ. ការបង្ការ ទប់ស្កាត់

#### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ១.១. ការអប់រំដោយផ្ទាល់

#### ១.១.២. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

នៅក្នុងខែតុលា ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងរៀបចំវេទិកាសាធារណៈការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់មន្ត្រីរាជការ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន **៩.៣៦៦**លើក មានអ្នកចូលរួមសរុបចំនួន **៥២៥.២៧២**នាក់ (ធៀបនឹងខែកញ្ញា មានចំនួន **៤១០.៧៩៥**នាក់ គឺមានការកើនឡើងចំនួន **១១៤.៤៧៧**នាក់ ស្មើនឹង**២៧,៨៦%**) ក្នុងនោះស្ត្រីចំនួន **២៨១.៦២៨**នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យកិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣២ | ១.៥៦៦ | ៨៨៨ | ៨០ | ៩.០០២ | ៥.៣៧០ |
| | សរុប ក្រសួង ស្ថាប័ន | ៣២ លើក | ១.៥៦៦ នាក់ | ៨៨៨ នាក់ | ៨០ លើក | ៩.០០២ នាក់ | ៥.៣៧០ នាក់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៧៧៤ | ៤៧.០២៦ | ២៥.៧៣៥ | ១.៩៨០ | ១៥២.២១៣ | ៧៦.៨៦៥ |
| ៣ | ខេត្តបាត់ដំបង | | | | | | |
| ៤ | ខេត្តពោធិ៍សាត់ | ៦៨០ | ៨០.៤៨៦ | ៤៧.៩៦៩ | ១៦៥ | ៥.៧៦៤ | ២.៧៨២ |
| ៥ | ខេត្តសៀមរាប | ២៥៥ | ១៣.៧៤៥ | ៧.៩៣៦ | ១៣ | ២៨៤ | ១៨៧ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.០៧៧ | ២៦.៦១៤ | ១៣.៨១៣ | ៥១៣ | ១១.០២២ | ៥.៨៦៧ |
| ៧ | ខេត្តកំពង់ចាម | ១.៦៥៥ | ៩៤.៤៤៧ | ៤៩.១៧៦ | ១.០៥៥ | ៣៣.៥៧៣ | ២០.៨៥៧ |
| ៨ | ខេត្តព្រះសីហនុ | ២១ | ១.៤០៧ | ៥២៤ | ១ | ៣២ | ១៧ |
| ៩ | ខេត្តព្រះវិហារ | ១ | ១០៩ | ៥៥ | | | |
| ១០ | ខេត្តស្វាយរៀង | | | | ២៨២ | ១០.០៨៤ | ៥.៦៨៧ |
| ១១ | ខេត្តប៉ៃលិន | ៦១ | ១.១៣៣ | ២៣៨ | ៤១ | ១.៦៣២ | ៣០៧ |
| ១២ | ខេត្តកោះកុង | ២ | ៩០២ | | | | |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ៣ | ១.០៦០ | ២៣៤ | | | |
| ១៥ | ខេត្តតាកែវ | ២៤៧ | ១០.៨០២ | ៥.៦៦៧ | ៩៤ | ៣.៤៦៦ | ១.៨៤១ |
| ១៦ | ខេត្តក្រចេះ | ១៥ | ១.៤២១ | ៥០៦ | | | |
| ១៧ | ខេត្តកែប | ២២ | ៥.១២៦ | ២.៩៦៤ | ៣១ | ១.៣៧៨ | ៨៤៧ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១៤០ | ៨.០៤១ | ៣.៥៣៥ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៤ | ១.៥៤០ | ៩៨៧ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៣ | ១៦០ | ៩៩ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ១១៩ | ១.២៣៧ | ៦៧៥ | | | |
| **សរុប រាជធានី-ខេត្ត** | | **៥.០៧៩លើក** | **២៩៥.២៥៦នាក់** | **១៦០.១១៣នាក់** | **៤.១៧៥លើក** | **២១៩.៤៤៨នាក់** | **១១៥.២៥៧នាក់** |
| **សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត** | | **ចំនួន ៩.៣៦៦ លើក** | | **ចំនួនមនុស្សសរុប ៥២៥.២៧២ នាក់** | | **ចំនួនស្ត្រី ២៨១.៦២៨ នាក់** | |

### ១.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តកណ្តាល៖** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈការចុះជួបសំណេះសំណាលសួរសុខទុក្ខគណៈគ្រប់គ្រងវិទ្យាល័យ លោកគ្រូ អ្នកគ្រូ ចំនួន០៦វិទ្យាល័យក្នុងខេត្ត ដោយមានអ្នកចូលរួមសរុប **៦៩**នាក់ ស្រី**០៤**នាក់។
- **ខេត្តសៀមរាប៖**
  - **លេខាធិការដ្ឋាន៖** បានរៀបចំកម្មវិធី ឆ្ពោះទៅមុខដើម្បីបញ្ចប់អំពើជួញដូរមនុស្ស ដោយសហការជាមួយអង្គការមូលនិធិអេ២១ប្រចាំកម្ពុជា មានអ្នកចូលរួមសរុប **៦០៥**នាក់ ស្រី**២៨០**នាក់។
  - **មន្ទីរអប់រំយុវជន និងកីឡា** បានប្រជុំផ្សព្វផ្សាយជាមួយក្រុមយុវជនស្ម័គ្រចិត្តស្តីពី ការការពារពីការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផលប៉ះពាល់ដោយអំពើជួញដូរមនុស្ស និងការប្រើប្រាស់គ្រឿងញៀន បានចំនួន **០១**លើក មានអ្នកចូលរួម **២០**នាក់ ស្រី**១០**នាក់។
  - **មន្ទីរទេសចរណ៍៖** បានចុះពង្រឹង និងទប់ស្កាត់ការជួញដូរមនុស្សមនុស្ស ក្នុងវិស័យទេសចរណ៍នៅតាមអាជីវកម្មស្នាក់នៅ ម៉ាស្សានិងស្ប៉ា ឌីស្កូតែក និងKTV បៀហ្គាឌិន បានចំនួន **១៩**លើក មានអ្នកចូលរួមសរុប **១៤៦**នាក់ ស្រី**១១៤**នាក់។

- **មន្ទីរឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖** បានធ្វើការបញ្ជ្រាបការផ្សព្វផ្សាយអំពីអំពើជួញដូរមនុស្ស នៅក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពហគ្រិនស្តីពី សារៈសំខាន់នៃការដំណើរការអាជីវកម្ម វេទិកាចលនាភូមិមួយផលិតផលមួយ បានចំនួន០៩លើក ដែលមានអ្នកចូលរួមសរុប **៣៧**នាក់ ស្រី**០៧**នាក់។
- **មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ៖** បានបញ្ជ្រាបការយល់អំពីបញ្ហាអំពើជួញដូរមនុស្ស នៅក្នុងពិធីសម្ពោធព្រះគណេស និងរូបសំណាកជារ៉ាវ៉ាលលូវើរ ទស្សនៈវិទូឥណ្ឌា បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ២០០នាក់ ស្រី១០០នាក់។

- **ខេត្តកំពង់ឆ្នាំង៖** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្សតាមរយៈកិច្ចតាមប្រព័ន្ធអនឡាញ ដល់ប្រធានការិយាល័យអប់រំ រដ្ឋបាលក្រុង ស្រុកទាំង៨ និងដល់សិស្សានុសិស្សនៅក្នុងពេលគោរពទង់ជាតិមុខចូលរៀន និងនៅក្នុងមេរៀនសាលាផងដែរ។
- **ខេត្តព្រៃវែង៖** រដ្ឋបាលខេត្តបានផ្សព្វផ្សាយអំពីការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ប្រជាពលរដ្ឋ និងចំណុះទូក ដែលមកចូលរួមកំសាន្តសប្បាយពិធីប្រណាំងទូក រៀបចំដោយរដ្ឋបាលខេត្ត ប្រមាណ ៦៨.៥២៥នាក់។

**១.១.៤. ការផ្សព្វផ្សាយរបស់អង្គការដៃគូ**

- **អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប)៖** ធ្វើការផ្សព្វផ្សាយដល់បុគ្គលិកមន្ទីរពេទ្យកុមារអង្គរ និងសហគមន៍ បានចំនួន ០៦លើក មានអ្នកចូលរួមសរុប ៦៩០នាក់(ស្រី៤០៤នាក់)។
- **អង្គការមូលនិធិអេ២១ អង្គការដំណក់ទឹក និងអង្គការកល្យាណមិត្ត (ខេត្តបន្ទាយមានជ័យ)៖** ធ្វើការអប់រំផ្សព្វផ្សាយដល់កុមារតាមដងផ្លូវស្តីពី សិទ្ធិកុមារនិងការការពារខ្លួនពីការកេងប្រវ័ញ្ចផ្សេងៗ ការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្សព្វផ្សាយពីសេវារបស់អង្គការ ចំនួន ០៤លើក មានអ្នកចូលរួមចំនួន ៦៤៩នាក់ ស្រី៣៦០នាក់។

**១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន **២.៤២៧**នាក់។
- **ខេត្តសៀមរាប៖** មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ **១៩១**លើក។
- **ខេត្តត្បូងឃ្មុំ៖** មន្ទីរពត៌មាន បានផ្សព្វផ្សាយតាមវិទ្យុ **១៤២**លើក។
- **ខេត្តព្រៃវែង៖** មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ **៥០**លើក។
- **ខេត្តតាកែវ៖** មន្ទីរព័ត៌មានបានផ្សព្វផ្សាយអំពីសកម្មភាពនានាពាក់ព័ន្ធ និងអំពើជួញដូរមនុស្ស ការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ គ្រឿងញៀន និងកិច្ចការពារជនរងគ្រោះ តាមរយៈឃ្លីបវីដេអូអប់រំ បានចំនួន **១.៧៦០**អត្ថបទ។

**១.៣. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

- **ខេត្តសៀមរាប៖** រដ្ឋបាលស្រុកពួក បានធ្វើការផ្សព្វផ្សាយ និងចែកខិតប័ណ្ណស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន **៤៥៩**ខិត្តប័ណ្ណ។
- **ខេត្តស្វាយរៀង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយរដ្ឋបាលក្រុងស្វាយរៀង បានធ្វើការផ្សព្វផ្សាយសារអប់រំស្តីពីចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ដែលមកទស្សនាពិធីប្រណាំងទូកនៅទន្លេវ៉ៃគោ ខេត្តស្វាយរៀង តាមរយៈ ផ្ទាំង poster អប់រំ ចំនួន **៥០០**ផ្ទាំង ។

- **អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ)៖** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ពលករ ចំនួន **១.៩៦៩**នាក់ (ស្រី**៧១៩**នាក់) កុមារ **២៣៧**នាក់ (កុមារី **១១២**នាក់)។ និងខិត្តប័ណ្ណផ្សព្វផ្សាយចំនួន **៤០៤**ច្បាប់។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

- **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការចុះអធិការកិច្ចជនបរទេស បានចំនួន **១៨**សហគ្រាស ពិនិត្យឃើញមានជនបរទេសចំនួន **១៨**នាក់(ស្រី**០៥**នាក់) ក្នុងនោះ អ្នកមានប័ណ្ណនិងសៀវភៅការងារ **១៥**នាក់ (ស្រី**០៥**នាក់)។

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **២១៩.៥១៣**នាក់ (ស្រី**៩៤.៨៧១**នាក់) អនីតិជន **៣.៩០៨**នាក់(ស្រី**១.៤៧៤**នាក់) ក្នុងនោះមាន៖
  - ស្របច្បាប់ ចំនួន **១៦៣.៩៨១**នាក់ (ស្រី**៧១.៥៤៦**នាក់) អនីតិជន **១.២២៥**នាក់(ស្រី**៥០៤**នាក់)
  - មិនស្របច្បាប់ចំនួន **៥៤.៨៤១**នាក់ (ស្រី**២៣.០២៥**នាក់) អនីតិជន **២.៥៧៩**នាក់(ស្រី**៩៤១**នាក់)
  - ដាច់ការទាក់ទងចំនួន **៦៩១**នាក់ (ស្រី **៣០០**នាក់) អនីតិជន **១០៤**នាក់(ស្រី**២៩**)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **៧៤.៩៦២**នាក់ (ស្រី**៣១.៨៧៨**នាក់) អនីតិជន **៤១៦**នាក់(ស្រី**១៥៦**នាក់)។
- **ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការទប់ស្កាត់ ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន **០៣**លើក មនុស្សចំនួន **១៩**នាក់(ស្រី**០៨**នាក់) អនីតិជន **០៣**នាក់ បានធ្វើកិច្ចសន្យាអប់រំ ណែនាំរួចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។

### ២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលក្រចេះ តាកែវ កំពង់ធំ កែប កំពង់ចាម ស្វាយរៀង ស្ទឹងត្រែង កំពង់ឆ្នាំង និងខេត្តសៀមរាប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន **១៣៣**គោលដៅ មនុស្សចំនួន **៣៣៤**នាក់(ស្រី**២៦៤**នាក់)។
  - កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ បាត់ដំបង កំពត ព្រះវិហារ និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើស ចំនួន **១៩**លើក។

### ២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ បានចំនួន **១០៦**នាក់(ស្រី**១០**នាក់) មាន **១៥**សញ្ជាតិ ហើយបានវាយតំលៃបញ្ជូនឱ្យក្រុមការងារច្រកចេញចូលតែមួយបានចំនួន **២១១**នាក់។ បានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងតាមរយៈទូរស័ព្ទ ចំនួន **០២**នាក់(ស្រី**១៦**នាក់) មានសេចក្តីសុខធម្មតា។

### ៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តក្រចេះ៖**
  - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារនៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ចំនួន **០១**លើក។
  - មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះផ្សព្វផ្សាយតាមបណ្តារោងចក្រសិប្បកម្មទឹកពិសារដេប ជញ្ជីងថ្លឹងទំងន់ ស្ថានីយ៍ប្រេងឥន្ធនៈ អំពីការកេងប្រវ័ញ្ចលើពលកម្មកុមារ ការទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើអំពើហិង្សាលើបុគ្គលិកកម្មករ (ពិសេសកុមារ) បានចំនួន**០២**មូលដ្ឋាន មានបុគ្គលិកចំនួន**០៨**នាក់ ស្រី**០២**នាក់។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រ សហគ្រាស កន្លែងលាងឡាន កន្លែងកំសាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ ០ឆ្នាំដល់៣ឆ្នាំ តាមស្រុក ឃុំ ភូមិគោលដៅមួយចំនួន។
- **ខេត្តព្រះសីហនុ៖** អង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញ ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍ ចំនួន **១.១៣៣**នាក់ ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

#### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **២៣**ករណី (ធៀបនឹងខែកញ្ញា មានចំនួន **១៨**ករណី កើន **០៥**ករណី ស្មើនឹង **២៧,៧៧%**) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **២៩**នាក់(ស្រី**០៣**នាក់) ជនសង្ស័យជាអនីតិជន**០៣**នាក់ ជនបរទេស**០៩**នាក់ មានជនជាតិចិន **០២**នាក់ វៀតណាម **០៦**នាក់ និងបង់ក្លាដេស **០១**នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន **៣៨**នាក់(ស្រី**២៧**នាក់) មានៈ អាយុក្រោម១៥ឆ្នាំ **១៦**នាក់ អាយុ១៥-១៧ឆ្នាំ **០២**នាក់ និងអាយុ១៨ឆ្នាំឡើង **២០**នាក់ (ប្រគល់ឱ្យសង្គមកិច្ច **០៦**នាក់ និងប្រគល់ឱ្យគ្រួសារ **៣២**នាក់) ក្នុងនោះបែកជា៖

❖ **ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **០៧/០១**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន **១១**នាក់ ជនបរទេស **០៧**នាក់ មានជនជាតិវៀតណាម **០៦**នាក់ បង់ក្លាដេស **០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **១៩**នាក់(ស្រី**០៨**នាក់) មានៈ អាយុក្រោម១៥ឆ្នាំ **០៣**នាក់ អាយុ១៥-១៧ឆ្នាំ **០១**នាក់ និងអាយុ១៨ឆ្នាំឡើង **១៥**នាក់ (ប្រគល់ឱ្យគ្រួសារ **១៩**នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ | ០១ | បង់ក្លាដេស០១ |
| -អំពើលក់ដូរមនុស្ស | ០២ | ០៦ | ០៣ | វៀតណាម០៣ |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០២ | ០៩ | ០៤ | វៀតណាម០២ |
| -ការទិញពេស្យាចារកុមារ | ០២ | ០៣ | ០៣ | វៀតណាម០១ |
| *សរុប* | *០៧ ករណី* | *១៩ នាក់* | *១១ នាក់* | *០៧ នាក់* |

❖ ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៦/១៧ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៨នាក់(ស្រី០៣នាក់) ជនសង្ស័យជាអនីតិជន ០៣នាក់ ជនជាតិចិន ០២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៩នាក់(ស្រី១៩នាក់) មាន: អាយុក្រោម១៥ឆ្នាំ ១៣នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០៥នាក់ (ប្រគល់ឱ្យសង្គមកិច្ច ០៦នាក់ ប្រគល់ឱ្យគ្រួសារ ១៣នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ចារកម្ម | ០១ | ០៣ | ០១ | ចិន០២ |
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០២ | ០៣ | ០៤ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១១ | ១១(អនី.០៣) | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ | ០២ | |
| *សរុប* | *១៦ ករណី* | *១៩ នាក់* | *១៨ នាក់(អនី.០៣)* | *០២ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ១.៧៩១នាក់(បុរស៨២៨នាក់ ស្ត្រី៦៦២នាក់ កុមារា១០៥នាក់ កុមារី ៩៦នាក់) សកម្មភាពមានដូចជា៖

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ:** បានទទួលចំនួន ០៦នាក់ (បុរស ០៣នាក់ កុមារី ០៣នាក់) មកពីប្រទេសចិន ០៣នាក់ ម៉ាឡេស៊ី ០៣នាក់ ជាករណីជួញដូរកម្លាំងពលកម្ម ០២នាក់ និងងាយរងគ្រោះ ០៤នាក់ បន្ទាប់ពីបានសម្ភាសន៍កំណត់អត្តសញ្ញាណបឋមរួច បានបញ្ជូនប្រុស ០៣នាក់ ទៅទទួលសេវាបន្តនៅអង្គការដៃគូ។
- **មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពលករចំណាកស្រុកដែលបញ្ជូនត្រឡប់មកពី ប្រទេសថៃ សរុបចំនួន ១.៧៨៥នាក់(បុរស ៩២៥នាក់ ស្ត្រី៦៦២នាក់ កុមារា១០៥នាក់ កុមារី៩៣នាក់) បានសម្ភាសកំណត់អត្តសញ្ញាណភេមុខសញ្ញា ជនរងគ្រោះ ជនងាយរងគ្រោះ និងកុមារមិនមានមនុស្សអមដំណើរមកជាមួយ និងផ្តល់ការស្នាក់នៅរយៈពេលខ្លីក្នុង មណ្ឌលសំចតមុនពេលបញ្ជូន ទៅទទួលសេវាបន្តនៅអង្គការដៃគូ និងសហគមន៍វិញ។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ជនរងគ្រោះដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន ០៨នាក់(ស្រី) មកពីប្រទេសចិន ករណីរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ។
- **ខេត្តបន្ទាយមានជ័យ៖** ស្នងការនគរបាលខេត្ត ពលករចូលតាមច្រកអូរបីជាន់ ច្រកបឹងត្រកួន ច្រកចំបក់ និងច្រកអន្តរជាតិប៉ោតប៉ែត ចំនួន ៤៣លើក មនុស្សចំនួន ១.០១៣នាក់ (ស្រី ៣៦៧នាក់) អនីតិជន ១២១នាក់។

- **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០២លើក មនុស្សចំនួន ០៣នាក់(ស្រី០១នាក់)។
- **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាម ចំនួន ០១លើក មនុស្សចំនួន ០៩នាក់(ស្រី០៦នាក់) អនីតិជន ០៦នាក់។

**២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ០៥នាក់(កុមារា ០៣នាក់ កុមារី ០២នាក់) ក្នុងនោះបានមកពីមន្ទីរ ស.អ.យ៖ ខេត្តបាត់ដំបង ០៣នាក់ និងខេត្តកំពង់ចាម ០២នាក់។ ជាករណីជួញដូរកម្លាំងពលកម្ម ០៤នាក់ និងរំលោភបំពានផ្លូវភេទ ០១នាក់។

**៣.ការធ្វើសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមវិញ**

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដែលបានធ្វើ សមាហរណកម្មត្រឡប់ទៅសហគមន៍វិញសរុបចំនួន ០៥នាក់ (ស្ត្រី០៣នាក់) មានករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ០៣នាក់ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ០២នាក់។

❖ ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលត្រូវបានបិទករណីចំនួន ០៧នាក់(ស្ត្រី០៣នាក់ កុមារី ០៤នាក់) មានករណី អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ០៣នាក់ ជួញដូរផ្លូវភេទ០២នាក់ និងរំលោភបំពានផ្លូវភេទ០២នាក់ មកពីអង្គការដៃកម្ពុជា០៤នាក់ និងអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា០៣នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

**១. ការងារបណ្តុះបណ្តាល**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** នាយកដ្ឋានគាំពារជនរងគ្រោះ សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) រៀបចំវគ្គបណ្តុះបណ្តាលលើគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់មន្ត្រីអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់សេវាសមស្របដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តរតនគិរី មានសិក្ខាកាមចូលរួម ២៨នាក់(ស្រី១៣នាក់)។

- **ខេត្តកំពង់ឆ្នាំង៖** មន្ទីរកិច្ចការនារី សហការជាមួយសមាគមន៍ភ្នំនាងកង្រី បើកវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ ចំណាកស្រុក និងអំពើជួញដូរមនុស្ស ដល់បណ្តាញស្ត្រីក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ចំនួន ០២វគ្គ មានអ្នកចូលរួម ៥៤នាក់ ស្រី០៩នាក់។

- **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សហការជាមួយក្រុមហ៊ុនចំនួន ០៣ បើកវគ្គបណ្តុះបណ្តាលអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពីបំនិនជីវិត ច្បាប់ស្តីពីការងារ និងការជួយសង្គ្រោះបឋម ចំនួន០៣វគ្គ មានសិក្ខាកាមចូលរួមសរុប ៦០នាក់ ស្រី៥៥នាក់។

- **ខេត្តត្បូងឃ្មុំ៖** រដ្ឋបាលស្រុកតំបែរ សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ ធ្វើការបណ្តុះបណ្តាលតាមមូលដ្ឋាន ស្តីពី ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព និងការជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋនៅឃុំតំបែរ និងឃុំគោកស្រុក ស្រុកតំបែរ មានអ្នកចូលរួម ៥៦នាក់។

**២. សិក្ខាសាលា**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) រៀបចំសិក្ខាសាលាស្តីពី «កិច្ចបង្ការការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងយន្តការរាយការណ៍អំពីរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ CSAM» នៅសណ្ឋាគារ Hyatt ភ្នំពេញ មានសិក្ខាកាមចូលរួម ៦៥នាក់ ស្រី ២១នាក់។

- **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន បានសហការជាមួយអង្គការវីនរ៉ក់អន្តរជាតិ បានរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ និងការដាក់ឱ្យអនុវត្តគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងខេត្តសៀមរាប បានចំនួន **០១**លើក មានអ្នកចូលរួម **៤០**នាក់ ស្រី**២៨**នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ៖
  - កិច្ចប្រជុំពិភាក្សារៀបចំសិក្ខាសាលាជាតិ ប្រមូលធាតុចូលសម្រាប់ផែនការជាតិបន្ត របស់ គ.ជ.ប.ជ ជាមួយតំណាងអង្គការវីនរ៉ក់អន្តរជាតិ (Winrock International) អង្គការអាស៊ានអាក់ (ASIAN-ACT) តំណាងពីអង្គការ IOM។
  - កិច្ចប្រជុំពិភាក្សាពិនិត្យលើអនុស្សរណៈយោគយល់រវាងអង្គភាពការពារកុមារ (CPU) នៃអង្គការមូលនិធិកុមារកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម **១៥**នាក់។
  - កិច្ចប្រជុំពិភាក្សាស្តីពី សំណើសុំរាជរដ្ឋាភិបាលកម្ពុជាផ្តល់ការបំភ្លឺ អំពីករណីជួញដូរមនុស្សនៅកម្ពុជា ជាមួយតំណាងអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ មានអ្នករួលរួម **២២**នាក់ ស្រី **០៤**នាក់។
  - កិច្ចប្រជុំពិភាក្សាស្តីពី កិច្ចការងារបន្ទាប់ពីបានចូលរួមក្នុងវេទិកាពិនិត្យឡើងវិញ លើទេសន្តរប្រវេសន៍អន្តរជាតិ (IMRF) និងការគាំទ្រដែលចាំបាច់នានា សម្រាប់ដោះស្រាយភាពប្រឈមក្នុងការអនុវត្តគោលបំណង GCM ជាមួយតំណាងអន្តរក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ មានអ្នកចូលរួម **១៩**នាក់ ស្រី **០៨**នាក់។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**
  - បានរៀបចំកិច្ចប្រជុំពិភាក្សាលើ សំណើសុំផ្តល់ព័ត៌មានបន្ថែម សម្រាប់គម្រោងអភិវឌ្ឍន៍សមត្ថភាពដើម្បីជួយអ្នករស់រានមានជីវិតពីការជួញដូរមនុស្សក្នុងប្រទេសកម្ពុជា ជាមួយតំណាង JICA តាមប្រព័ន្ធអនឡាញ នៅនាយកដ្ឋានគាំពារជនរងគ្រោះ។
  - បានរៀបចំកិច្ចប្រជុំពិភាក្សាការងារ រវាងនាយកដ្ឋានគាំពារជនរងគ្រោះជាមួយ អង្គការវីនរ៉ក់អន្តរជាតិ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) និងអង្គការរតនៈអ៊ិនធើណេសិនណល នៅនាយកដ្ឋានគាំពារជនរងគ្រោះ។
  - បានរៀបចំកិច្ចប្រជុំចុះហត្ថលេខាលើកិច្ចព្រមព្រៀងលើគម្រោង "អភិវឌ្ឍន៍សមត្ថភាព ដើម្បីជួយអ្នករស់រានមានជីវិតពីការជួញដូរមនុស្សក្នុងប្រទេសកម្ពុជា" រវាងនាយកដ្ឋានគាំពារជនរងគ្រោះ នៃក្រសួង ស.អ.យ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) នៅទីស្តីការក្រសួងស.អ.យ។

### ២. ការងារជំនួបពិភាក្សា

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអនុញ្ញាតឲ្យតំណាងអង្គការ ណូមីណេតវើក (Nomi Nretwork) ចូលជួបសម្តែងការគួរសម និងសំណេះសំណាលការងារអំពីទស្សនវិស័យ និងគោលបំណងរបស់អង្គការ ដែលមានបេសកកម្មចំបងៗ គឺការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់ដើមទុនសម្រាប់អាជីវកម្មខ្នាតតូច ដល់ស្ត្រីងាយរងគ្រោះ ដើម្បីចូលរួមកាត់បន្ថយការធ្វើចំណាកស្រុក។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** លោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌល បានចូលរួមកិច្ចសម្ភាសន៍ការងារជាមួយ អង្គការ UNWOMEN តាមប្រព័ន្ធអនឡាញ និងជួបពិភាក្សាការងារជាមួយ អង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) លើគម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើសំណាកស្រុកដោយសុវត្ថិភាព។
- **ខេត្តបន្ទាយមានជ័យ៖** លោកស្រី **រស់ សុផានី** បានអនុញ្ញាតអោយអង្គការចិត្តសង្គមអន្តរវប្បធម៌ ជួបពិគ្រោះយោបល់ស្តីពីការជ្រើសរើស និងចាត់តាំងមន្ត្រីជួរមុខដែលបម្រើការការងារជូនពលករចំណាកស្រុកដែលវិលត្រឡប់មកវិញ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលទាក់ទងនឹងសុខភាពផ្លូវចិត្តអ្នកផ្តល់សេវានៅសាលាខេត្តបន្ទាយមានជ័យ។
- **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បាន៖
  - ទទួលជួបផ្តល់កិច្ចសម្ភាសន៍ ស្តីពីការទទួលបានជ័យលីភ័យលើការអនុវត្តសេវាសង្គម ជាមួយក្រសួងមហាផ្ទៃ ចំនួន **០១**លើក នៅបន្ទប់ប្រជុំ Video Conference សាលាខេត្ត។
  - បានទទួលជួបពិភាក្សាការងារជាមួយ ប្រតិភូតំណាងរាជរដ្ឋាភិបាល អង្គការហាការ និងអង្គការ Hope Trust នៃប្រទេសកោះសាលមុន តាមរយៈអង្គការមូលធិហាការអន្តរជាតិប្រចាំប្រទេសកម្ពុជា ដើម្បីស្វែងយល់អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងខេត្តសៀមរាប ចំនួន**០១**លើក។
  - បានទទួលជួបផ្តល់កិច្ចសម្ភាសន៍ជាមួយ អ្នកស្រាវជ្រាវរបស់អង្គការ UN Women ស្តីពី ការលើកកម្ពស់ និងគាំទ្រលើស្ត្រីពលករទេសន្តរប្រវេសន៍ នៅក្នុងវិបត្តិជំងឺកូវីដ-១៩ ចំនួន **០១**លើក។
  - **ក្រុមការងារស្រុកពួក** បានជួបពិភាក្សាការងារជាមួយអង្គការ IOM ស្តីពីការចុះសម្ភាសន៍ជាមួយពលករចំណាកស្រុកក្នុងអំឡុងពេលធ្វើការងារក្នុងប្រទេសថៃ បានចំនួន **០១**លើក។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៥០**លើក មានអ្នកចូលរួមសរុប **១.៧៦៧**នាក់(ស្រី**២៦៥**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **១០**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **០៤**លើក និង លេខាធិការដ្ឋានរាជធានី ខេត្ត **៣៦**លើក។**(ឧបសម្ព័ន្ធ១)**

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជាៈ

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្ដល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្ដល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្ដីសម្រេច ស្ដីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្ដេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។

- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែវិច្ឆិកា ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ..........ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី...០៧...ខែ.....ធ្នូ.....ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"**ដើម្បីគោរពជូនជាសេចក្តីរាយការណ៍**"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"**ដើម្បីជូនជ្រាប**"

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន ៥០លើក ) មនុស្សចំនួន ១.៧៦៧នាក់ (ស្រី ២៦៥នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ( គ.ជ.ប.ជ ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ចូលរួមជាគណៈអធិបតីបើកកម្មវិធីព្យុហយាត្រា "ឆ្ពោះទៅមុខដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស" ដែលរៀបចំដោយអង្គការមូលនិធិ A21 សហការជាមួយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប មានអ្នកចូលរួមប្រមាណ **៦០០**នាក់។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ចូលរួមកិច្ចប្រជុំពិភាក្សារៀបចំ សិក្ខាសាលាជាតិប្រមូលធាតុចូលសម្រាប់ផែនការជាតិបន្ត របស់ គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**។<br>- ចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងកែសម្រួលខ្លឹមសារ អនុស្សរណៈយោគយល់រវាង គ.ជ.ប.ជ ជាមួយអង្គការដៃនដីមនុស្សហូឡង់ដ៏ ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**។<br>- ចូលរួមកិច្ចប្រជុំពីផែនការសកម្មភាពនៃគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់អង្គការដៃគូចំនួន ០៣( IOM, IJM, CARITAS CAMBODIA ) ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**។<br>- ចូលរួមកិច្ចប្រជុំ ពិភាក្សាស្តីពី ការស្នើសុំបន្តពិនិត្យលើអនុស្សរណៈនៃការយោគយល់រវាង អង្គភាពការពារកុមារ ( CPU ) នៃអង្គការមូលនិធិកុមារកម្ពុជា និង ពិនិត្យកែសម្រួលលើខ្លឹមសារ ពាក្យពេចន៍ឲ្យបានសមស្រប ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**។<br>- អមដំណើរ**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** ចូលរួមជាគណៈអធិបតីបើកកម្មវិធីព្យុហយាត្រា "ឆ្ពោះទៅមុខដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស" ដែលរៀបចំដោយអង្គការមូលនិធិ A21 សហការជាមួយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប។<br>- ចុះសួរសុខទុក្ខស្ត្រីរកស៊ីពពោះជំនួស ចំនួន០២នាក់ និងកូនភ្លោះទាំងពីរគូ ដែលកំពុងស្នាក់មន្ទីរពេទ្យ១៦ឧសភា ក្រសួងមហាផ្ទៃ ហើយបានណែនាំអោយស្ត្រីទាំងពីនាក់ជាម្តាយថែទាំសុខភាពទាំងខ្លួនឯង និងទារក ព្រមទាំងជំរុញអោយស្ត្រីជាម្តាយយកទារកទៅចុះសំបុត្រកំណើត និងយកទារកចាក់វ៉ាក់សាំងអោយបានទៀងទាត់។ ៧ |

- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៣៧ច្បាប់ លិខិតចូល ០៧ច្បាប់។
  - លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៥ច្បាប់ លិខិតចូល ១១ច្បាប់។
  - ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន ១១៥ច្បាប់។
  - អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ២១សកម្មភាព។
  - អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ២៥ច្បាប់។
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - ចូលរួមកិច្ចប្រជុំពិភាក្សារៀបចំ សិក្ខាសាលាជាតិប្រមូលធាតុចូលសម្រាប់ផែនការជាតិបន្ត របស់ គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។**
  - ចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងកែសម្រួលខ្លឹមសារ អនុស្សរណៈយោគយល់រវាង គ.ជ.ប.ជ ជាមួយអង្គការដែនដីមនុស្សហូឡង់ដ៏ ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។**
  - ចូលរួមកិច្ចប្រជុំពីផែនការសកម្មភាពនៃគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់អង្គការដៃគូចំនួន ០៣(IOM, IJM, CARITAS CAMBODIA) ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។**
  - ចូលរួមកិច្ចប្រជុំ ពិភាក្សាស្តីពី ការស្នើសុំបន្តពិនិត្យលើអនុស្សរណៈនៃការយោគយល់រវាង អង្គភាពការពារកុមារ (CPU) នៃអង្គការមូលនិធិកុមារកម្ពុជា និង ពិនិត្យកែសម្រួលលើខ្លឹមសារ ពាក្យពេចន៍ឲ្យបានសមស្រប ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។**
  - អមដំណើរ**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** ចូលរួមជាគណៈអធិបតីបើកកម្មវិធីព្យុហយាត្រា "ឆ្ពោះទៅមុខដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស" ដែលរៀបចំដោយ អង្គការមូលនិធិ A21 សហការជាមួយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប
  - បានចូលរួមចុះសួរសុខទុក្ខស្ត្រីកេស៊ីពពោះជំនួស ចំនួន០២នាក់ និងកូនភ្លោះទាំងពីរគូ ដែលកំពុងស្នាក់មន្ទីរពេទ្យ១៦ឧសភា ក្រសួងមហាផ្ទៃ ជាមួយលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ.**ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - ចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាល និងបញ្ជាការពារ ស្តីពី ការផ្តល់ប្រឹក្សាពាក់ព័ន្ធនិងអំពើហិង្សា ការរំលោភបំពានគ្រប់ទម្រង់ នៅខេត្ត ព្រះវិហារ មានសិក្ខាកាមចូលរួម ៤៦នាក់ ស្រី ០៣នាក់។
  - ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមការងារបច្ចេកទេស នៅខេត្តសៀមរាប មានអ្នកចូលរួម ៥០នាក់ ស្រី ០៨នាក់។

- បានចូលរួមចុះសួរសុខទុក្ខស្ត្រីរកស៊ីពពោះជំនួស ចំនួន០២នាក់ និងកូនក្មេងទាំងពីរគូ ដែលកំពុងស្នាក់មន្ទីរពេទ្យ១៦ឧសភា ក្រសួងមហាផ្ទៃ ជាមួយលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ.**ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ។

- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - ចូលរួមកិច្ចប្រជុំពីផែនការសកម្មភាពនៃគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់អង្គការដៃគូចំនួន ០៣( IOM, IJM, CARITAS CAMBODIA ) ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។**
  - បានអមដំណើរ **លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ** ចូលជួប ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីសុំការណែនាំ កែតម្រូវពាក្យពេចន៍ និងឃ្លោងឃ្លាមួយចំនួននៅក្នុងអនុស្សរណៈយោគយល់រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដែនដីមនុស្សហូឡង់ដ៏ប្រចាំកម្ពុជា ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។
  - ចូលរួមប្រជុំជាមួយក្រុមគ្រូបង្គោលរបស់ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ដើម្បីពិនិត្យខ្លឹមសារលើសេចក្តីព្រាងនៃសេចក្តីសម្រេចស្តីពី ការបង្កើតក្រុមគ្រូបង្គោល និងអ្នកសម្របសម្រួល សម្រាប់បណ្តុះបណ្តាលការងារជំនាញពាក់ព័ន្ធ ក្រោមការដឹកនាំដោយ **លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ** នៅសាលប្រជុំគ.ជ.ប.ជ។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**
  - ចូលរួមកិច្ចប្រជុំពិភាក្សារៀបចំ សិក្ខាសាលាជាតិប្រមូលធាតុចូលសម្រាប់ផែនការជាតិបន្ត របស់ គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។**
  - លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយ UN-WOMEN ដែលបានធ្វើការបង្ហាញអំពីគម្រោងវត្តខ្លី រយៈពេលមួយឆ្នាំរបស់ខ្លួនគិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ខែ កុម្ភៈ ឆ្នាំ២០២៣ អំពីផលប៉ះពាល់ពីជំងឺកូវីដ-១៩ អំពើហិង្សា និងបញ្ហាយេនឌ័រ ដែលមាន គោលដៅលើខេត្តចំនួន៤ គឺខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង និងឧត្តរមានជ័យ។
  - ចូលរួមធ្វើបទបង្ហាញក្នុងសិក្ខាសាលាស្តីពី "សមភាពយេនឌ័រ ពិការភាព និងបរិយាប័ន្នសង្គម សិទ្ធិជនរងគ្រោះ និងការតាមដាន ការវាយតម្លៃ និងការរៀនសូត្រ" ដែលបានរៀបចំឡើងដោយ ASEAN-ACT។

- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**
  - ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** និងលោក ឧត្តមសេនីយ៍ទោ **ស្រី សាមឌី** បានចូលរួមសិក្ខាសាលាស្តីពី ការពង្រឹងច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិនៅកម្ពុជា ទាក់ទងនឹងទេសន្តរប្រវេសន៍ការងារដោយផ្តោតលើវិស័យនេសាទ និងកែច្នៃអាហារសមុទ្រនៅអាស៊ីអាគ្នេយ៍ ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការ ILO ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
  - ចូលរួមប្រជុំជាមួយក្រុមគ្រូបង្គោលរបស់ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ដើម្បីពិនិត្យខ្លឹមសារលើសេចក្តីព្រាងនៃសេចក្តីសម្រេចស្តីពី ការបង្កើតក្រុមគ្រូបង្គោល និងអ្នកសម្របសម្រួល សម្រាប់បណ្តុះបណ្តាលការងារជំនាញពាក់ព័ន្ធ ក្រោមការដឹកនាំដោយ **លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ** នៅសាលប្រជុំគ.ជ.ប.ជ។

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖**<br>- លោកឧត្តមសេនីយ៍ត្រី **តែ សុថារេត** អគ្គលេខាធិការរង និងជាសមាជិកអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងារ របស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិច អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ(អ.អ.ផ) បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៦ នៃ អ.អ.ផ ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ.អ.ផ នៅសណ្ឋាគារ ហាយយ៉ាត់ រីជេនស៊ី ភ្នំពេញ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - លោក **យូ សុភ័ក្រ** ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ ដឹកនាំមន្ត្រីជំនាញពាក់ព័ន្ធ បានសហការនិងចូលរួមជាមួយប្រតិភូភាគីថៃ ក្នុងការចុះពិនិត្យការដ្ឋានសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីធ្វើការទូទាត់លើកទី២។<br>- បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធករណីសំណើសុំគោលការណ៍ត្រួតពិនិត្យ និងកែសម្រួលលើសារាចរណែនាំ ស្តីពី ការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ នៅនាយកដ្ឋានអភិវឌ្ឍន៍គោលនយោបាយ។<br>- បានចូលរួមសិក្ខាសាលាស្តីពី សមភាពយេនឌ័រ បរិយាប័ន្នសង្គម សិទ្ធិជនរងគ្រោះ ការតាមដានវាយតម្លៃ និងការរៀនសូត្រ រៀបចំដោយ ASEAN-ACT នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ។<br>- បានចូលរួមសិក្ខាសាលាស្តីពី កិច្ចបង្ការការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងយន្តការរាយការណ៍អំពីរូបភាពសម្ភាររំលោភបំពានកុមារ "CSAM" នៅសណ្ឋាគារ Hyatt Regency។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣៦លើក អ្នកចូលរួមសរុបចំនួន ១.០៧១នាក់(ស្រី ២៥៤នាក់)** | |
| **ខេត្តសៀមរាប** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន**០១**លើក អ្នកចូលរួម **៥២**នាក់ ស្រី**២៦**នាក់។<br>- លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំត្រៀមរៀបចំកម្មវិធី ឆ្ពោះទៅមុខដើម្បីបញ្ចប់អំពើជួញដូរមនុស្ស **០១**លើក មានអ្នកចូលរួម **១៤**នាក់ ស្រី**១០**នាក់។<br>- ប្រជុំក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រុង-ស្រុក ចំនួន **០៦**លើក អ្នកចូលរួម **១៥៥**នាក់ ស្រី**៧៣**នាក់។ |
| **ខេត្តកណ្តាល** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ **០១**លើក មានអ្នកចូលរួម **២៦**នាក់ ស្រី**១៩**នាក់។<br>- ក្រុមការងារក្រុង ស្រុក-ប្រជុំប្រចាំខែ ចំនួន **០៧**លើក អ្នកចូលរួម **១៧៩**នាក់ ស្រី**៧៤**នាក់។<br>- លោកជំទាវ **ហ៊ុន កុសនី** អភិបាលរង នៃគណៈអភិបាលខេត្ត៖ **១.**បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឲ្យអនុវត្តផែនការសកម្មភាពជាតិគាំពារ និងអភិវឌ្ឍកុមារ (២០២២-២០២៣) ដែលរៀបចំដោយគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍនកុមារ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។ **២.**បានចូលរួមធ្វើជាគណៈអធិបតីភាព ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើការរៀបចំផែនការកិច្ចការពារកុមារខេត្តកណ្តាល នៅសាលប្រជុំសាលាខេត្ត មានអ្នកចូលរួម **៦១**នាក់។ |
| **ខេត្តកំពង់ចាម** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន**០១**លើក។<br>- លោកជំទាវ **ប៉ាង ដានី** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងាររយៈពេល៩ខែ របស់ គ.ជ.ប.ជ មានអ្នកចូលរួម **៤២**នាក់ ស្រី**២៦**នាក់។ |
| **ខេត្តស្វាយរៀង** | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍រយៈពេល ៩ខែ ឆ្នាំ២០២២ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ ចំនួន **០១**លើក។ |

| | |
|---|---|
| | - បានចូលរួមកិច្ចប្រជុំគ្រោះយោបល់ស្តីពី ការបង្កើតផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូមនុស្ស (២០២២-២០២៣) នៅអគារ Kampus រាជធានីភ្នំពេញ។ |
| **ខេត្តតាកែវ** | - លោកស្រី **គា សុភូ** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គ.ខ.ប.ជ បានចូលរួមប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំអំពើរជួញដូរមនុស្ស រយៈពេល ០៩ខែ ឆ្នាំ២០២២។<br>- និងចូលរួមសិក្ខាសាលាស្តីពី ការរៀបចំការបង្កើតផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(២០២២-២០២៣) ចំនួន **០១**លើក។ |
| **ខេត្តព្រៃវែង** | - បានប្រជុំផ្សព្វផ្សាយផែនការកិច្ចការពារកុមារខេត្តឆ្នាំ២០២៣-២០២៥ មានអ្នកចូលរួម **៤៧**នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន**០១**លើក។ |
| **ខេត្តមណ្ឌលគិរី** | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើការរៀបចំផែនការកិច្ចការពារកុមារខេត្ត រយៈពេល៣ឆ្នាំ(២០២២-២០២៥) នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡា។ |
| **ខេត្តត្បូងឃ្មុំ** | - ឯកឧត្តមបណ្ឌិត **ជាម ច័ន្ទសោភ័ណ** អភិបាល នៃគណៈអភិបាលខេត្ត ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត និងជាប្រធានគ.ខ.ប.ជ បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ដើម្បីក្តាប់សភាពការណ៍ក្នុងការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ មានអ្នកចូលរួមប្រមាណ **៤២០**នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ការកំណត់អត្តសញ្ញាណកម្មជនរងគ្រោះ និងក្រមសីលធម៌ក្នុងការសម្ភាសន៍ ដែលរៀបចំដោយអង្គការសម្ព័ន្ធចាប់ដៃ មានសិក្ខាកាមចូលរួម **៣៥**នាក់ ស្រី**២៦**នាក់។ |
| **ខេត្តបន្ទាយមានជ័យ** | - ឯកឧត្តម **អ៊ុំ រាត្រី** អភិបាលខេត្ត បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឲ្យអនុវត្តន៍ ផែនការសកម្មភាពជាតិគាំពារកុមារ និងអភិវឌ្ឍកុមារតូច ឆ្នាំ ២០២២ -២០២៦ សណ្ឋាគារភ្នំពេញ។<br>- លោកស្រី **រស់ សុផានី** ប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំស្តីពី ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- និងបានចូលរួមវេទិកាអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៦ ឆ្នាំ២០២២ ក្រោមប្រធានបទ «សូមកុំយកកម្ពុជា ជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស!»។<br>- លោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត និងមន្ត្រីជំនាញ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីៈ **១**.ការគ្រប់គ្រងករណីលើការវិលត្រឡប់ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ **២**.ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូតមនុស្ស នៅក្រុងព្រះសីហនុ។<br>- និងបានចូលរួមកិច្ចប្រជុំស្តីពី បច្ចុប្បន្នភាពធ្វើលើពលករចំណាកស្រុកក្នុងវិស័យនេសាទ និងអាហារតាមរយៈសកម្មភាពរបស់មជ្ឈមណ្ឌលធនធានពលករទេសន្តរ ប្រវេសន៍ ប្រចាំខេត្តបន្ទាយមានជ័យ។ |
| **ខេត្តកំពង់ស្ពឺ** | - លោកស្រីឧត្តមសេនីយ៍ត្រី **ធីន សុគន្ធា** ស្នងការរងទទួលផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមកិច្ចប្រជុំថ្នាក់ខេត្តស្តីពី ការរៀបចំផែនការកិច្ចការពារកុមារខេត្ត រយៈពេល៣ឆ្នាំ(២០២៣-២០២៥) មានអ្នកចូលរួម **៤០**នាក់។ |
| **ខេត្តស្ទឹងត្រែង** | - បានចូលរួមប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំអំពើរជួញដូរមនុស្ស រយៈពេល ០៩ខែ ឆ្នាំ២០២២ របស់ គ.ជ.ប.ជ **០១**លើក។ |